មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំដែលបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតការណ៍សវនាការរបស់ខ្លួននៅសាលាឧទ្ធរណ៍

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១

ថ្ងៃនេះ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពី *"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍"* ដែលធ្វើឡើងចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។ របាយការណ៍នេះវិភាគលើទិន្នន័យ ដែលប្រមូលបានតាមរយៈការសង្កេតការណ៍សវនាការប្រចាំថ្ងៃលើសំណុំរឿងព្រហ្មទណ្ឌចំនួន ២០៣ ករណី ដោយមិនបានកំណត់ជាក់លាក់លើសំណុំរឿងណាមួយនៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញ និងបានប្រើប្រាស់តារាងសង្កេតការណ៍សវនាការ ដែលបានតាក់តែងយ៉ាងច្បាស់លាស់ក្នុងគោលបំណងវាយតម្លៃលើការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានកំណត់នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

របាយការណ៍នេះបានបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅមុខសាលាឧទ្ធរណ៍ រួមមានសិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនពេលជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ។ លើសពីនេះទៅទៀត សាលាឧទ្ធរណ៍បានការពារយ៉ាងស៊ីសង្វាក់នូវការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះអំពើល្មើសដដែល និងការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។

ប៉ុន្តែគួរឱ្យសោកស្តាយ ការសង្កេតការណ៍សវនាការក៏បានរកឃើញកង្វះការអនុលោមតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាមូលដ្ឋានមួយចំនួន ដូចបានបង្ហាញនៅខាងក្រោម៖។

- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ត្រូវបានចាត់ថ្នាក់ថាមិនត្រូវបានគោរពពេញលេញ ដោយហេតុថានៅតែមានជនជាប់ចោទជាច្រើនដែលអះអាងថាពួកគេទទួលរងនូវអំពើហិង្សា ឬការធ្វើទារុណកម្មដើម្បីបង្ខំឱ្យពួកគេសារភាពថាបានប្រព្រឹត្តបទល្មើសដែលបានចោទប្រកាន់ (ជនជាប់ចោទចំនួន ១៧ នាក់ក្នុងចំណោម ២៥៥ នាក់)។ បន្ថែមលើនេះ ជនជាប់ចោទពីរនាក់បានលើកឡើងថា ពួកគេត្រូវបានគំរាមគំហែងឱ្យសារភាព។

- សិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះជាសាធារណៈមិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ ដោយសារមានតែសវនាការចំនួន ១៥% ប៉ុណ្ណោះនៃសវនាការដែល ម.ស.ម.ក បានសង្កេតការណ៍មានបិទកាលវិភាគសវនាការនៅលើក្ដារខៀននៅខាងក្រៅបន្ទប់សវនាការ។
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់បន្តត្រូវបានចាត់ទុកថា មិនទាន់ត្រូវបានគោរពពេញលេញនៅឡើយ។ ខណៈដែលចៅក្រមបានប្រាប់ជនជាប់ចោទអំពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ប្រឆាំងនឹងខ្លួនចំនួន ៧៨,៣% នៃសំណុំរឿងដែលបានសង្កេតការណ៍ ចៅក្រមខកខានក្នុងការប្រាប់សិទ្ធិនេះជាងមួយភាគប្រាំនៃសំណុំរឿង ដែលជាការខ្វះខាត។
- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការជាទូទៅមិនទាន់ត្រូវបានគោរពៈ ចំនួន ២៨% នៃជនជាប់ចោទពុំមានមេធាវីតំណាងឡើយ ដែលការគោរពថយចុះទាបគួរឱ្យព្រួយបារម្ភជាងរបកគំហើញកាលពីឆ្នាំមុន (ប្រមាណចំនួន ២៦% នៃជនជាប់ចោទគ្មានមេធាវីតំណាងនៅឆ្នាំ២០១៨/២០១៩)។ជាងនេះទៅទៀត សំណុំរឿងចំនួន ១៥ នៅក្នុងចំណោមសំណុំរឿងដែល ម.ស.ម.ក បានសង្កេតការណ៍ ចៅក្រមពុំបានប្រាប់ជនជាប់ចោទអំពីសិទ្ធិមានមេធាវីឡើយ ដែលនេះគឺជានិន្នាការគួរឱ្យព្រួយបារម្ភមួយ។ ស្រដៀងគ្នានេះដែរ ខណៈដែលចំនួនជនជាប់ចោទមានវត្តមានក្នុងសវនការរបស់ខ្លួនបានកើនឡើង បើប្រៀបធៀបទៅឆ្នាំមុន (ចំនួន ១៩% នៃជនជាប់ចោទអវត្តមាននៅពេលសវនាការនៅឆ្នាំ២០១៨/២០១៩) ចំនួន ១០% នៃជនជាប់ចោទអវត្តមាននៅពេលសវនាការនៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍។
- ការសន្មតទុកជាមុនថាគ្មានទោសនៅតែមិនទាន់ត្រូវបានគោរពពេញលេញ ដោយចៅក្រមមិនបានប្រាប់ជនជាប់ចោទចំនួន ២៥,៦% អំពីសិទ្ធិនៅស្ងៀមរបស់ពួកគេ ហើយចំនួន ២៨,២% នៃជនជាប់ចោទបានបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានដូចគ្នាទៅនឹងឯកសណ្ឋានរបស់ទណ្ឌិតដែរ។
- សិទ្ធិបង្ហាញភស្តុតាងមិនត្រូវបានគោរពពេញលេញ។ នៅក្នុងសំណុំរឿងចំនួនមួយនៃសំណុំរឿងចំនួនពីរដែលសាក្សីត្រូវបានកោះហៅ សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលពួកគេត្រូវបានសាកសួរ ដែលនេះអាចនាំឱ្យមានការជះឥទ្ធិពលលើសក្ខីកម្មរបស់ពួកគេ ដោយការឮសក្ខីកម្មរបស់សាក្សីផ្សេងទៀតមុនពេលផ្ដល់ភស្តុតាង។
- ចៅក្រមនៃសាលាឧទ្ធរណ៍ក៏ខកខានគោរពឱ្យបានពេញលេញ នូវសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុនៅក្នុងសំណុំរឿងដែលបានសង្កេតការណ៍ ដោយមានចំនួនស្មើតែ ៦៥% នៃសេចក្ដីសម្រេចមិនបានផ្ដល់សំអាងហេតុគ្រប់គ្រាន់។
- សិទ្ធិរបស់ជនជាប់ចោទជាអនីតិជនដែលត្រូវបានការពារ ជាពិសេសនៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់ជាតិកម្ពុជា នៅតែបន្តមិនគោរពផងដែរៈ ពុំមានវិធានការពិសេសណាមួយត្រូវបានដាក់ឱ្យអនុវត្តដើម្បីការពារឯកជនភាពរបស់អនីតិជនឡើយនៅក្នុងសវនាការដែលបានសង្កេតការណ៍។ បន្ថែមលើនេះ

ជនជាប់ចោទជាអនីតិជនទាំងអស់ពាក់ព័ន្ធនឹងសំណុំរឿងដែលបានសង្កេតការណ៍ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

របាយការណ៍នេះក៏ធ្វើការប្រៀបធៀបទិន្នន័យឆ្នាំនេះជាមួយនឹងទិន្នន័យឆ្នាំ ២០១៤/២០១៥ ឆ្នាំ២០១៦/២០១៧ ឆ្នាំ២០១៧/២០១៨ និងឆ្នាំ២០១៨/២០១៩ ផងដែរ ដើម្បីកំណត់និន្នាការ និងវិភាគការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជារួម សិទ្ធិទទួលបានការជំនុំជម្រះជាច្រើនត្រូវបានគោរពយ៉ាងស៊ីសង្វាក់ដោយសាលាឧទ្ធរណ៍ចាប់តាំងពីឆ្នាំ២០១៤ មក រួមមានសិទ្ធិក្នុងការជួបសន្ទនាជាមួយមេធាវីមុនពេលជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ ការហាមឃាត់ការអនុវត្តអានុភាពប្រតិសកម្មនៃច្បាប់ និងការការពារប្រឆាំងនឹងការវិនិច្ឆ័យទោសពីរដងចំពោះអំពើល្មើសដដែល។ ប៉ុន្តែសិទ្ធិមួយចំនួនមិនទាន់ត្រូវបានគោរពពេញលេញចាប់តាំងពីឆ្នាំ២០១៤ មក ដូចជាសិទ្ធិទទួលការជំនុំជម្រះជាសាធារណៈ សិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ សិទ្ធិបង្ហាញភស្តុតាង និងសិទ្ធិរបស់អនីតិជនជាដើម។ ជាចុងក្រោយ សិទ្ធិមួយចំនួន ដែលត្រូវបានចាត់ចំណាត់ថ្នាក់ថាត្រូវបានគោរពដោយសាលាឧទ្ធរណ៍កាលពីឆ្នាំមុន ត្រូវបានប្តូរទៅចំណាត់ថ្នាក់នៃសិទ្ធិមិនទាន់ត្រូវបានគោរពពេញលេញនៅប៉ុន្មានឆ្នាំថ្មីៗនេះ។ សិទ្ធិទាំងនេះរួមមាន៖

- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ដែលត្រូវបានចាត់ចំណាត់ថ្នាក់ថាត្រូវបានគោរពពេញលេញនៅឆ្នាំ២០១៤/២០១៥ ប៉ុន្តែចាប់តាំងពីពេលនោះមក មិនត្រូវបានគោរពពេញលេញដោយសាលាឧទ្ធរណ៍។ ជាពិសេស ចៅក្រមសាលាឧទ្ធរណ៍បានខកខានប្រាប់ ឬពន្យល់ជនជាប់ចោទអំពីសិទ្ធិនៅស្ងៀម ហើយចំនួនកើនឡើងនៃជនជាប់ចោទដែលបង្ហាញខ្លួននៅមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារចាប់តាំងពីឆ្នាំ២០១៤ មក។
- សិទ្ធិយល់ដឹងអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ ដែល ម.ស.ម.ក បានរកឃើញថាត្រូវបានការពារនៅក្នុងឆ្នាំ២០១៤/២០១៥ និងឆ្នាំ២០១៦/២០១៧ ត្រូវបានប្តូរទៅផ្នែក "មិនទាន់ត្រូវបានគោរពពេញលេញ" នៅក្នុងឆ្នាំ២០១៧/២០១៨ និង២០១៨/២០១៩។ ការសង្កេតការណ៍នៅឆ្នាំនេះបានបង្ហាញថា សិទ្ធិនេះមិនទាន់បានគោរពពេញលេញ៖ ទោះបីជាចៅក្រមបានប្រាប់អំពីការចោទប្រកាន់ពាក់ព័ន្ធទាំងអស់ប្រឆាំងនឹងជនជាប់ចោទទាំងអស់ នៅក្នុងសំណុំរឿងចំនួន ៧៨,៣% ដែលចំនួននេះមានការកើនឡើងគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងចំនួន ៦៧,៤% នៅក្នុងឆ្នាំ២០១៨/២០១៩ ម.ស.ម.ក បានកត់សម្គាល់អំពីការធ្លាក់ចុះភាគរយនៃសំណុំរឿងដែលចៅក្រមបានប្រាប់អំពីច្បាប់ពាក់ព័ន្ធទីកន្លែង និងបទល្មើស និងភាគីពាក់ព័ន្ធ បើប្រៀបធៀបនឹងអំឡុងពេលធ្វើរបាយការណ៍កាលពីមុន។

- សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ដែលត្រូវបានចាត់ទុកថាត្រូវបានគោរពពេញលេញនៅឆ្នាំ២០១៤/២០១៥ ហើយចាប់តាំងពីពេលនោះមក ត្រូវបានចាត់ចំណាត់ថ្នាក់ថាមិនត្រូវបានគោរពពេញលេញ។ ភាគរយនៃជនជាប់ចោទ ដែលមានមេធាវីតំណាង ត្រូវបានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៤/២០១៥ មក។ លើសពីនេះ ស្ទើរតែពុំមានសំណុំរឿង ដែលជនជាប់ចោទមានវត្តមាន ចៅក្រមបានប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវី ឬការការពារខ្លួនដល់ពួកគេ។
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពពីពិរុទ្ធភាព ដែលបន្ទាប់ពីត្រូវបានចាត់ទុកថាត្រូវបានការពារនៅឆ្នាំ២០១៧/២០១៨ ត្រូវបានចាត់ចំណាត់ថ្នាក់ឡើងវិញថាមិនទាន់ត្រូវបានគោរពពេញលេញនៅឆ្នាំ២០១៨/២០១៩ ដោយសារតែមានការលើកឡើងដោយជនជាប់ចោទថា ការសារភាពរបស់ពួកគេបានមក តាមរយៈអំពើហិង្សា ឬទារុណកម្ម។ ថ្វីបើនិន្នាការនៅឆ្នាំ២០១៨/២០១៩ បង្ហាញថាមានការធ្លាក់ចុះតិចតួច បើប្រៀបធៀបនឹងឆ្នាំ២០១៧/២០១៨ ទិន្នន័យដែលប្រមូលបាននៅអំឡុងពេលធ្វើរបាយការណ៍ឆ្នាំ២០១៩/២០២០ បង្ហាញថា ចំនួននៃជនជាប់ចោទដែលលើកឡើងពីហិង្សា ឬទារុណកម្ម ត្រូវបានប្រើប្រាស់ប្រឆាំងនឹងពួកគេ បានកើនឡើងម្តងទៀត ដែល ជាបញ្ហាគួរឱ្យព្រួយបារម្ភ និងអំពាវនាវឱ្យមានការស៊ើបអង្កេតជាបន្ទាន់ និងឱ្យបានហ្មត់ចត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍នេះអាចរកបាននៅលើគេហទំព័រ ម.ស.ម.ក ជាភាសាខ្មែរ និងភាសាអង់គ្លេស និងទិន្នន័យដើមអាចរកបាននៅលើប្រព័ន្ធទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ហ៊ុន ស៊ាងហាក់ អ្នកសម្របសម្រួលគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក តាមរយៈអ៊ីមែល seanghak.hun@cchrcambodia.org ឬលេខទូរស័ព្ទ +៨៥៥ (០) ១២ ៤០ ៣០ ៥០។

– **ចប់** –

**បណ្ណាធិការៈ**

## អំពីគម្រោងសង្កេតការណ៍សវនាការ

គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានចាប់តាំងពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌក្នុងតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តបទដ្ឋានជាតិ និងអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌។ គម្រោងបានប្រើប្រាស់នូវរបកគំហើញដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។ គោលបំណងរួមរបស់គម្រោងគឺ ធ្វើឱ្យមានភាពប្រសើរឡើងផ្នែកនីតិវិធី និងការអនុវត្តរបស់តុលាការកម្ពុជាដែលធានាថាមានការ

គោរពយ៉ាងពេញលេញនូវបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងសវនាការព្រហ្មទណ្ឌ ព្រមទាំងបង្កើនការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ព្រមទាំងទិន្នន័យសង្កេតការណ៍សវនាការ។ ឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងគម្រោងអាចរកបាននៅទីនេះ។

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ត្រូវបានបង្កើតនៅខែវិច្ឆិកា ឆ្នាំ២០០២ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងកម្ពុជា។ ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ធនាអន្តជាតិដើម្បីសេរីភាពសម្តែងមតិ (IFEX) ជាបណ្តាញសកលលោកដើម្បីសេរីភាពសម្តែងមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រប់ការរួមរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិកនៃបណ្តាញប្រឆាំងនឹងទារុណកម្ម អែស អូ អែស និងជាសមាជិក OECD-Watch។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសបែន (Brisbane)នៃប្រទេសអូស្ត្រាលី។